# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

# សេចក្តីណែនាំបច្ចេកទេស

## សម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតប
## គ្រោះអាសន្ន
## នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានីភ្នំពេញ
ខែមិថុនា ឆ្នាំ ២០១៣

# មាតិកា


អារម្ភកថា

I. សេចក្តីផ្តើម ............................................................................................១

II. ទម្រង់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ............................................................................................ ២

III. សេចក្តីណែនាំពីការសរសេរតាមផ្នែកនីមួយៗក្នុងការរៀបចំកសាងផែនការ ត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ......................៤

IV. ដំណើរការសម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ............................................................................១២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឲ្យប្រើប្រាស់ផែនការជាតិត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយតាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម) ដើម្បីឲ្យមានការបម្រុងទុកជាក់លាក់រួចជាស្រេច នូវធនធានមនុស្ស សម្ភារៈ បច្ចេកទេស សម្រាប់ឆ្លើយតបទៅនឹងគ្រោះមហន្តរាយនៅថ្នាក់ជាតិ។ រីឯនៅថ្នាក់ក្រោមជាតិវិញ ការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះអាសន្ន ត្រូវបានផ្តួចផ្តើមរៀបចំនូវផែនការសម្រាប់អនុវត្តនៅថ្នាក់ខេត្ត ស្រុកមួយចំនួន ដែលបានការឧបត្ថម្ភពីអង្គការដៃគូ ដែលធ្វើសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ប៉ុន្តែខ្លឹមសារផែនការដែលថ្នាក់ខេត្ត ស្រុក បានរៀបចំនៅមានកម្រិត និងមានលក្ខណៈខុសៗគ្នា។

ដើម្បីឲ្យការអនុវត្តមានការឯកភាពស៊ីសង្វាក់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការ UNICEF បានរៀបចំសេចក្តីណែនាំបច្ចេកទេសនេះឡើង សម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន សំដៅជួយឲ្យដំណើរការអនុវត្តពិតប្រាកដ ជាក់ស្តែងជាបទដ្ឋានរួមមួយក្នុងការរៀបចំកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងធ្វើឲ្យផែនការនេះ មានប្រសិទ្ធភាពក្នុងការអនុវត្ត ហើយក៏បានរួមបញ្ចូលផងដែរនូវវិធានការដែលមានទិសដៅធ្វើឲ្យប្រាកដថា ត្រូវមានការឆ្លើយតបយ៉ាងពេញលេញមួយក្នុងករណីមានគ្រោះអាសន្នកើតឡើង។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូទាំងអស់ ដែលបានចំណាយពេលវេលា កម្លាំងកាយ ចិត្ត ស្មារតី ចំណេះដឹង បទពិសោធន៍ និងថវិកា ចូលរួមរៀបចំសេចក្តីណែនាំបច្ចេកទេស សម្រាប់ការរៀបចំដំណើរការ និងរបៀបរបបរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយឈរលើស្មារតីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងកាត់បន្ថយផលវិបាកដ៏អាក្រក់ដល់ប្រជាជន និងសហគមន៍ងាយរងគ្រោះ ហើយដែលជាការចាំបាច់បំផុត សូមស្នើដល់គ្រប់ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ទាំងអស់ ជួយចូលរួមគាំទ្រក្នុងការធ្វើឲ្យផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឲ្យលេចជារូបរាងឡើងពិតប្រាកដជាក់ស្តែង ងាយស្រួលក្នុងការត្រៀមមុនជាស្រេចដើម្បីឆ្លើយតបគ្រោះអាសន្ន ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣

**បណ្ឌិត ញឹម វណ្ណដា**

**ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី១ គ.ជ.គ.ម**

# I. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាធ្លាប់ជួបប្រទះគ្រោះមហន្តរាយធំៗជាញឹកញាប់ដូចជាគ្រោះទឹកជំនន់ ឆ្នាំ២០០០ ២០០១ ២០០២ គ្រោះរាំងស្ងួតធ្ងន់ធ្ងរឆ្នាំ២០០៣ ២០០៤ ព្យុះកំបុតត្បូងដែលកម្ពុជាពុំធ្លាប់ជួបប្រទះបានកើតមានឡើងនៅចុងខែកញ្ញា និងដើមខែតុលា ឆ្នាំ២០០៩ ដែលមានឈ្មោះថា "ព្យុះកេតសាណា" ហើយនៅចុងខែកញ្ញាឆ្នាំ២០១១ កើតមានទឹកជំនន់ទន្លេមេគង្គ និងជំនន់ទឹកភ្លៀងនៅតំបន់ភ្នំផងដែរ។ ក្រៅពីនេះក៏មានគ្រោះមហន្តរាយបណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ដូចជា៖ រន្ទះបាញ់ ខ្យល់កន្ត្រាក់ អគ្គីភ័យ ជំងឺឆ្លងរាតត្បាត បាក់ច្រាំងទន្លេ។ល។

យើងឃើញថាគ្រោះមហន្តរាយដោយធម្មជាតិដែលពីមុនមិនធ្លាប់មានបានកើតមានហើយកាន់តែញឹកញាប់ និងមានវិសាលភាពដែលបណ្តាលឲ្យបាត់បង់អាយុជីវិតមនុស្ស សត្វ ខូចខាតហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងឯកជន ប៉ះពាល់ជីវភាពរស់នៅព្រមទាំងធ្វើឲ្យមានភាពក្រីក្រ។ ផលប៉ះពាល់ដល់អាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាជន គឺមានលក្ខណៈខុសៗគ្នា អ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេគឺ ស្ត្រី កុមារ ជនពិការ ចាស់ជរា និងស្ត្រីមានផ្ទៃពោះ។ ជាងនេះទៅទៀតពួកគេប្រឈមទៅនឹងការថែទាំសុខភាព ការអប់រំ ការរស់រានមានជីវិតក្នុងភាពថ្លៃថ្នូរ ព្រមទាំងសមត្ថភាពរបស់ពួកគេក្នុងការស្តារស្ថានភាពគ្រួសារឡើងវិញឲ្យបានរហ័ស។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយដោយចាំបាច់ត្រូវមានផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នជាមុន ដោយឆ្លុះបញ្ចាំងអំពីផលវិបាកដ៏អាក្រក់ដែលកើតមានចំពោះប្រជាជន និងសហគមន៍ ជាពិសេសក្រុមងាយរងគ្រោះរួមមាន៖ កុមារ ស្ត្រី ជនពិការ ចាស់ជរា និងស្ត្រីមានផ្ទៃពោះ។ ការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺមានលក្ខណៈខុសៗគ្នា និងទៅតាមកម្រិតយល់ដឹងខុសៗគ្នាផងដែរ។

សេចក្តីណែនាំបច្ចេកទេសដែលបានបង្កើតឡើងនេះសំដៅជួយឲ្យមានជាបទដ្ឋានរួមមួយដើម្បីឲ្យដំណើរការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយក៏ទទួលបាននូវការយល់ព្រមពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើឲ្យផែនការនេះកើតមានឡើងពិតប្រាកដ ជាក់ស្តែង មានប្រសិទ្ធភាព និងងាយស្រួលក្នុងការអនុវត្តដែលត្រូវការធ្វើការពិចារណាលើភាពខុសគ្នានៃភាពងាយរងគ្រោះមួយចំនួន។

សេចក្តីណែនាំបច្ចេកទេសសម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុង ឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងក្រោមការណែនាំរបស់ថ្នាក់ដឹកនាំគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការចូលរួមជាគំនិតយោបល់ និងទស្សនៈពីអ្នកពាក់ព័ន្ធជាច្រើននៅឆ្នាំ២០១២ ក្រោមកិច្ចសហប្រតិបត្តិការរៀបចំសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសដោយមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មន្ត្រីជំនាញលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្រសួងមហាផ្ទៃ ព្រមទាំងក្រុមការងារបច្ចេកទេសរបស់អង្គការ UNICEF និងដៃគូអភិវឌ្ឍន៍មួយចំនួនទៀត ដែលអនុវត្តគម្រោងកម្មវិធីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុ ។

## II. ទម្រង់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

មាតិកាបទដ្ឋានរួមនៃផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ដែលអាចពង្រីកបន្ថែមបានដើម្បីអោយសមស្របទៅតាមតម្រូវការរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) រួមមាន៖

**អារម្ភកថា**

**១. សេចក្តីផ្តើម**

**២. បរិបទរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

២.១ រចនាសម្ព័ន្ធរដ្ឋបាល និងផែនទី
២.២ ភូមិសាស្ត្រ
២.៣ ប្រជាសាស្ត្រ
២.៤ សេដ្ឋកិច្ច និងជីវភាព
២.៥ ហេដ្ឋារចនាសម្ព័ន្ធ និងតំបន់សុវត្ថិភាព
២.៦ វិស័យសុខាភិបាល អប់រំ ទឹកស្អាត និងអនាម័យ
២.៧ វប្បធម៌ និងសាសនា
២.៨ ក្រុមងាយរងគ្រោះ
២.៩ ព័ត៌មាន និងទិន្នន័យគ្រោះមហន្តរាយ
២.១០ ផែនទីបង្ហាញមុខសញ្ញាគ្រោះថ្នាក់ និងស្ថានភាពហានិភ័យ

**៣. ប្រព័ន្ធផ្តល់ព័ត៌មានជាមុន**

**៤. យន្តការ រចនាសម្ព័ន្ធ និងសកម្មភាពយុទ្ធសាស្ត្ររបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ**

៤.១ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត និងក្រុមទាំង៤
៤.២ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមទាំង៤
៤.៣ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ និងក្រុមទាំង៣
៤.៤ យន្តការសម្របសម្រួល

## ៥. ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន


៥.១ សេណារីយ៉ូដែលទំនងកើតឡើងបំផុត

៥.១.១ ហានិភ័យទី១ / សេណារីយ៉ូទី១

៥.១.២ ហានិភ័យទី២ / សេណារីយ៉ូទី២

៥.២ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

៥.២.១ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់ហានិភ័យទី១

៥.២.២ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់ហានិភ័យទី២


## ៦. ធនធាន


៦.១ ធនធានសម្ភាររបស់ស្ថាប័ន

៦.២ ធនធានសម្ភារ និងឧបករណ៍

៦.៣ ធនធានមនុស្ស

៦.៤ ទីទួលសុវត្ថិភាព

៦.៥ ចំងាយផ្លូវពីសាលាក្រុង ស្រុក ខណ្ឌ ទៅឃុំ សង្កាត់

៦.៦ ព័ត៌មានអំពីទំនិញ ស្បៀងអាហារ និងពូជធារ

៦.៧ ប្រព័ន្ធធារាសាស្ត្រ


## ៧. ឧបសម្ព័ន្ធ


៧.១ បញ្ជីទំនាក់ទំនង

៧.២ ផែនទីស្រុកទាំងឡាយរបស់ខេត្ត

៧.៣ ទម្រង់បែបបទប៉ាន់ប្រមាណឆាប់រហ័ស

៧.៤ ទម្រង់បែបបទប៉ាន់ប្រមាណតាមវិស័យ

៧.៥ សំណើកញ្ចប់បទដ្ឋានរួមសម្រាប់ចែកចាយ

៧.៦ ធម្មនុញ្ញស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយរបស់កុមារ

៧.៧ ផែនទីអ្នកពាក់ព័ន្ធ

៧.៨ ផ្សេងៗតាមការពាក់ព័ន្ធ

## III. សេចក្តីណែនាំពីការសរសេរតាមផ្នែកនីមួយៗក្នុងការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### អារម្ភកថា

ផ្នែកនេះគួរសរសេរនៅទំព័រដាច់ដោយឡែកបន្ទាប់ពីទំព័រនៃមាតិកា។ ខ្លឹមសារផ្នែកនេះគួរសរសេរខ្លីបំផុតដោយគ្រាន់តែពិពណ៌នាអំពីព័ត៌មានសំខាន់ៗមួយចំនួនដូចជា៖

(ក) សារៈសំខាន់នៃផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

(ខ) សេចក្តីថ្លែងអំណរគុណចំពោះស្ថាប័នពាក់ព័ន្ធ និងបុគ្គលដែលបានចូលរួមនៅក្នុងដំណើរការកសាងផែនការ

(គ) សេចក្តីសង្ឃឹមទុកជាមុនថាផែនការនឹងត្រូវបានអនុវត្តព្រមទាំងទទួលបានការចូលរួមគាំទ្រពីស្ថាប័នពាក់ព័ន្ធរួមទាំងស្ថាប័នរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជនផងដែរ។

អារម្ភកថាចុះហត្ថលេខា និងប្រថាប់ត្រាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### ១. សេចក្តីផ្តើម

សេចក្តីផ្តើមគួរពន្យល់បកស្រាយអំពីមូលហេតុសំខាន់ៗ គោលបំណង និងដំណើរការនៃការកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន។ ផ្នែកនេះក៏ត្រូវសរសេរសង្ខេបខ្លីយ៉ាងច្រើនបំផុតត្រឹម ១ ឬ ២ ទំព័រប៉ុណ្ណោះ ។

### ២. ព័ត៌មានពីបរិបទរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ព័ត៌មានក្នុងផ្នែកនេះត្រូវសរសេរព័ត៌មានសង្ខេបនៅតាមផ្នែកសំខាន់ៗខាងក្រោម ៖

២.១ រចនាសម្ព័ន្ធរដ្ឋបាល និងផែនទី៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.២ ភូមិសាស្ត្រ៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៣ ប្រជាសាស្ត្រ៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៤ សេដ្ឋកិច្ច និងជីវភាព៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៥ ហេដ្ឋារចនាសម្ព័ន្ធ និងតំបន់សុវត្ថិភាព៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៦ វិស័យសុខាភិបាល អប់រំ ទឹកស្អាត និងអនាម័យ៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២.៧ វប្បធម៌ និងសាសនា៖ ព័ត៌មានក្នុងផ្នែកនេះដកស្រង់ព័ត៌មានពីក្នុងសៀវភៅទិន្នន័យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ២.៨. ព័ត៌មានពីក្រុមងាយរងគ្រោះ៖ នៅក្នុងផ្នែកនេះត្រូវសង្ខេបព័ត៌មានពីភាពងាយរងគ្រោះតាមវិស័យសំខាន់ៗដូចខាងក្រោម៖

### ព័ត៌មានភាពងាយរងគ្រោះផ្នែកមនុស្ស

| ស្រុក | ឃុំ | ប្រភេទ | | | | | | | | | មុខសញ្ញាគ្រោះថ្នាក់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្ត្រី | កុមារ 0-5 ឆ្នាំ | កុមារ 6-18 ឆ្នាំ | ចាស់ជរា | ជនពិការ | អ្នកជំងឺរុំារ៉ៃ | គ្រួសារក្រីក្រ | | | ទឹកជំនន់ | រាំងស្ងួត | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | |

### ព័ត៌មានភាពងាយរងគ្រោះផ្នែកកសិកម្ម

| ស្រុក | ឃុំ | ប្រភេទដំណាំ | | | | | | | | | | មុខសញ្ញាគ្រោះថ្នាក់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្រូវប្រាំង (ហត) | ស្រូវវស្សា (ហត) | ពោត (ហត) | ដំឡូង (ហត) | សណ្តែកបាយ (ហត) | សណ្តែកសៀង (ហត) | សណ្តែកដី(ហត) | បន្លែ (ហត) | | | ទឹកជំនន់ | រាំងស្ងួត | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | |

### ព័ត៌មានភាពងាយរងគ្រោះផ្នែកសត្វ

| ស្រុក | ឃុំ | ប្រភេទសត្វ | | | | | | | | | | មុខសញ្ញាគ្រោះថ្នាក់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | គោ | ក្របី | ជ្រូក | មាន់ | ទា | សេះ | ពពែ | ចៀម | | | ទឹកជំនន់ | រាំងស្ងួត | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | |

### ២.៩ ព័ត៌មាន និងទិន្នន័យគ្រោះមហន្តរាយ

ក្នុងផ្នែកនេះជាព័ត៌មានសង្ខេបពីប្រវត្តិ និងទិន្នន័យនៃគ្រោះមហន្តរាយនានាដែលបានកើតឡើងកន្លងមក។ ព័ត៌មាននេះគួរសរសេរសង្ខេបខ្លីៗនូវព័ត៌មាន និងទិន្នន័យស្តីពីការខូចខាតតាមវិស័យនីមួយៗដែលបណ្តាលមកពីគ្រោះមហន្តរាយកន្លងមក ៖

ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ (សាលារៀន/ផ្ទះសម្បែង/វត្តអារាម/មន្ទីរពេទ្យ/មណ្ឌលសុខភាព/អាគាររដ្ឋបាល/ផ្លូវថ្នល់/ទំនប់/ប្រឡាយ)។

ផ្នែកកសិកម្ម/ផលិតកម្ម៖ (ស្រូវប្រាំង/វស្សា/ពោត/ដំឡូង/សណ្តែកបាយ/សណ្តែកសៀង/សណ្តែកដី/បន្លែ)។

ផ្នែកសង្គមកិច្ច៖ ដើម្បីគាំទ្រនូវព័ត៌មានសង្ខេបខាងលើ តារាងឧបសម្ព័ន្ធដែលមានព័ត៌មានលម្អិតពីប្រភេទគ្រោះមហន្តរាយ ឆ្នាំនៃការកើត និងការខូចខាតតាមវិស័យនីមួយៗគួររៀបចំហើយភ្ជាប់ជាឧបសម្ព័ន្ធ។

### ២.១០ ផែនទីបង្ហាញមុខសញ្ញាគ្រោះថ្នាក់ និងស្ថានភាពហានិភ័យ

ផ្នែកនេះគ្រាន់តែភ្ជាប់ផែនទីដែលមានព័ត៌មានពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងហានិភ័យនៃគ្រោះមហន្តរាយរបស់ថ្នាក់រាជធានី ខេត្ត  ក្រុង ស្រុក និង ខណ្ឌ។

## ៣. ប្រព័ន្ធផ្តល់ព័ត៌មានជាមុន

ផ្នែកនេះត្រូវសរសេរអំពីមធ្យោបាយ និងរាល់ឧបករណ៍ចាំបាច់ក្នុងការព្យាករណ៍ទឹកជំនន់ ធាតុអាកាស និងផ្សព្វផ្សាយព័ត៌មាន ។

## ៤. យន្តការ រចនាសម្ពន្ធ័ និងសកម្មភាពយុទ្ធសាស្ត្ររបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

### ៤.១, ៤.២, ៤.៣ យន្តការ រចនាសម្ពន្ធ័ និងសកម្មភាពយុទ្ធសាស្ត្រ៖

ផ្នែកនេះ ចំណុច ៤.១, ៤.២, ៤.៣ ត្រូវយោងព្រះរាជក្រឹត្យ និងអនុក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអនុក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់។

- រាជធានី ខេត្ត
  -រចនាសម្ព័ន្ធគ្រប់គ្រង
  -តួនាទី និងការទទួលខុសត្រូវ
  -ព័ត៌មានទំនាក់ទំនង និងការសហការសម្របសម្រួល
  -ចំនួនក្រុមការងារ/ក្រុមប្រតិបត្តិ

- ក្រុង ស្រុក ខណ្ឌ
  - រចនាសម្ព័ន្ធគ្រប់គ្រង
  - តួនាទី និងការទទួលខុសត្រូវ
  - ព័ត៌មានទំនាក់ទំនង និងការសហការសម្របសម្រួល
  - ចំនួនក្រុមការងារ /ក្រុមប្រតិបត្តិ

- ឃុំ សង្កាត់
    - រចនាសម្ព័ន្ធគ្រប់គ្រង
    - តួនាទី និងការទទួលខុសត្រូវ
    - ព័ត៌មានទំនាក់ទំនង និងការសហការសម្របសម្រួល
    - ចំនួនក្រុមការងារ /ក្រុមប្រតិបត្តិ

ព័ត៌មានលម្អិតរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅតាមថ្នាក់នីមួយៗសូមដាក់ជាឧបសម្ព័ន្ធ (ឧបសម្ព័ន្ធលេខ............)។

### ៤.៤ យន្តការសម្របសម្រួល

ក្នុងផ្នែកនេះត្រូវសរសេរពីសកម្មភាពគួរអនុវត្តមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ៥. ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

### ៥.១ សេណារីយ៉ូដែលទំនងកើតឡើងបំផុត

ក្នុងផ្នែកនេះការបង្កើតសេណារីយ៉ូ គឺជាលំហាត់ដែលត្រូវពិចារណាអំពីលទ្ធភាពដែលអាចឆ្លើយតបទៅនឹងគ្រោះមហន្តរាយ (ផ្នែកខាងក្នុង និងផ្នែកខាងក្រៅ )។ ការពិភាក្សា និងការឯកភាពគ្នាលើយុទ្ធសាស្រ្តឆ្លើយតប និងនៅលើកម្រិតផ្សេងៗគ្នា ដោយយោងទៅលើសក្តានុពលនៃសេណារីយ៉ូដែលបានដឹងជាមុនថានឹងកើតឡើងក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (កម្រិតផ្សេងគ្នានៃការខូចខាត )។

៥.១.១ ហានិភ័យទី១ / សេណារីយ៉ូទី១

៥.១.២ ហានិភ័យទី២ / សេណារីយ៉ូទី២

### ៥.២ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

៥.២.១ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់ហានិភ័យទី១

៥.២.២ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នសម្រាប់ហានិភ័យទី២

| វិស័យ | គោលបំណង | វិធានការ/ សកម្មភាព | អ្នកទទួលខុសត្រូវ (អ្នកដឹកនាំអ្នកអនុវត្ត) | ពេលវេលា | ធនធាន និងថវិកា |
|---|---|---|---|---|---|
| សុខភាព | ១) | ១.១ | | | |
| | | ១.២ | | | |
| | ២) | ២.១ | | | |
| | | ២.២ | | | |

ផ្នែកនេះត្រូវសរសេររាល់វិធានការសកម្មភាពដែលត្រូវអនុវត្តក្នុងពេលគ្រោះមហន្តរាយរបស់វិស័យនីមួយៗដោយផ្អែកលើសេណារីយ៉ូដែលបានកំណត់ខាងលើ (សេណារីយ៉ូសម្រាប់ហានិភ័យ ទី១, ទី២...)។

ការបំពេញផែនការត្រៀមឆ្លើយតបរបស់សេណារីយ៉ូនីមួយៗតាមតារាងខាងលើ។

សម្គាល់៖ ប្រសិនបើខេត្តចង់បង្កើតផែនការត្រៀមបង្ការបន្ថែម (ប្រើទម្រង់ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នខាងលើ) ឬប្រសិនបើខេត្តមានផែនការនេះរួចហើយសូមភ្ជាប់ជាឧបសម្ព័ន្ធ។

# ៦. ធនធាន

## ៦.១ ធនធានសម្ភាររបស់ស្ថាប័ន

| ស្ថាប័ន/អង្គការ | អ្នកទទួលខុសត្រូវ | ធនធានសំខាន់ៗ | | | | | | | | | | | | | តំបន់គោលដៅ | ថវិកាប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | រថយន្តដឹកទំនិញ | រថយន្តសង្គ្រោះបន្ទាន់ | រថយន្តពន្លត់អគ្គិភ័យ | ម៉ាស៊ីនបូមទឹក | បាវខ្សាច់ | តង់/ជម្រកចល័ត | ធុងចម្រោះទឹក | ទឹក | សាប៊ូ (ដុំ/កញ្ចប់) | ថ្នាំពេទ្យ | អាហារស្ងួត/ត្រៀម | ទូក/កាណូត | អង្ករ (តោន) | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | | |

តារាងខាងលើនេះត្រូវជ្រើសរើសតែធនធានសំខាន់ៗ ដែលស្ថាប័ន/អង្គការមានក្នុងការឆ្លើយតបគ្រោះអាសន្ន។

## ៦.២. ធនធានសម្ភារ និងឧបករណ៍

| ស្ថាប័ន/អង្គការ | ចំនួន | មធ្យោបាយ និងឧបករណ៍ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | រថយន្តដឹកទំនិញ | រថយន្តសង្គ្រោះបន្ទាន់ | រថយន្តពន្លត់អគ្គិភ័យ | ចប | ចបកាប់ | ប៉ែល | កន្ត្រក | អាវការពារ | ខ្សែពួរ | ថ្នាំពេទ្យ | តង់ | ផ្ទះចល័ត | ........ | ផ្សេងៗ |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | |

## ៦.៣. ធនធានមនុស្ស

| ស្ថាប័ន/អង្គការ | ចំនួនបុគ្គលិក | ប្រភេទធនធានមនុស្ស<br>(ឧទាហរណ៍៖ អ្នកស្ម័គ្រចិត្តក្រុមជួយសង្គ្រោះ អ្នកជំនាញ ។ល។) |
|---|---|---|
| | | |
| | | |
| សរុប | | |

### ៦.៤. ទីទួលសុវត្ថិភាព

| ក្រុង-ស្រុក | ឃុំ-សង្កាត់ងាយរងគ្រោះ | ចំនួនភូមិចំណុះងាយរងគ្រោះ | ចំនួនទីទួលសុវត្ថិភាព | ចំនួនអណ្តូង | ចំនួនបង្គន់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្រុកបរិបូណ៌ | ឆ្នុកទ្រូ | ២ | ១ | ១ | ១ | ដីលោក ឈិន គឹមឃន ភូមិស្វាយគយ ឃុំពន្លៃ (១,៨គ.ម ពីសាលាស្រុក, ផ្លូវជាតិលេខ ៥២) |
| | ខុនរ៉ង | ២ | ១ | 0 | 0 | វត្តត្រពាំងពោធិ ឃុំខុនរ៉ង (៥គ.ម ពីសាលាស្រុក, ផ្លូវលំក្រួសក្រហម) |
| | កំពង់ព្រះគគីរ | ៤ | ១ | ២ | ១ | វត្តស្រះកែវ ឃុំមេលំ (ចម្ងាយ ១៣គ.ម ពីសាលាស្រុក, ផ្លូវជាតិលេខ៥) |
| | ផ្សារ | ១ | ១ | ២ | ១ | វត្តជយោរង្សី ហៅវត្តបន្ទាយធ្លក ឃុំផ្សារ (ចម្ងាយ ៧គ.ម ពីសាលាស្រុក, ផ្លូវជាតិលេខ៥ និងផ្លូវលំ) |
| សរុប | | | | | | |

ក្នុងផ្នែកនេះត្រូវសរសេរព័ត៌មានស្តីពីទីទួលសុវត្ថិភាពសំខាន់ៗ នៅក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហើយត្រូវបញ្ជាក់អោយបានច្បាស់ពីស្ថានភាពរបស់ទីទួលសុវត្ថិភាពទាំងនោះ ប្រសិនបើមានបរិក្ខារដែលអាចប្រើប្រាស់បានក្នុងពេលមានគ្រោះមហន្តរាយកើតឡើង ។

### ៦.៥. ចម្ងាយផ្លូវពីសាលាក្រុង ស្រុក ខណ្ឌ ទៅកាន់សាលារាជធានី ខេត្ត ឃុំ សង្កាត់នានា

| សាលាក្រុង ស្រុក ខណ្ឌ | ចម្ងាយផ្លូវ (គីឡូម៉ែត្រ) | ស្ថានភាព និងទីផ្សារ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

តារាងនេះ គឺសម្រាប់បំពេញព័ត៌មានអំពីចម្ងាយផ្លូវ (គិតជាគីឡូម៉ែត្រ)។ ចម្ងាយផ្លូវនេះត្រូវយកចំណុចទីរួមខេត្តជាគោលសម្រាប់ជាចំណុចចាប់ផ្តើមនៃការកំណត់ពីចម្ងាយផ្លូវទៅកាន់ទីតាំងសាលាក្រុង ឬសាលាស្រុក ខណ្ឌទាំងអស់របស់ខេត្ត (ក្នុងមួយតារាងគឺសម្រាប់តែមួយស្រុកប៉ុណ្ណោះ)។ បន្ទាប់ពីបានកំណត់ចម្ងាយផ្លូវសម្រាប់ក្រុង ឬ ស្រុក ខណ្ឌ រួចហើយ អ្នករៀបចំត្រូវគណនាជាបន្តទៀតពីចម្ងាយផ្លូវសម្រាប់ឃុំ ឬ សង្កាត់ទាំងអស់ដែលមានក្នុងក្រុង ឬ ស្រុក ខណ្ឌរបស់ខ្លួនដោយកំណត់យកទីតាំងគោលចេញពីសាលាក្រុង ឬ សាលាស្រុក ខណ្ឌ ទៅកាន់ឃុំ សង្កាត់ទាំងនោះ។

## ៦.៦. ព័ត៌មានអំពីទំនិញស្បៀងអាហារ និងសម្ភារ

| ល.រ | ឈ្មោះម្ចាស់ហាង | ឈ្មោះទំនិញ | បរិមាណស្តុក ក្នុង១ខែ គិតជាមធ្យម | តម្លៃប៉ាន់ស្មាន | ទីតាំង/ អាសយដ្ឋាន | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|---|---|---|
| I | ផ្នែកលក់ស្បៀង(អង្ករ) | | | | | |
| ១ | | អង្ករចំរុះ | ២០តោន | ១,៩០០៛/គក្រ | ផ្សារលើ | |
| ២ | | អង្ករចំរុះ | ៣០តោន | ១,៨០០៛/គក្រ | ឃុំស្រែថ្មី | |
| ៣ | | | | | | |
| II | ផ្នែកលក់គ្រឿងបរិភោគ | | | | | |
| ១ | | មីយើង | ២០០កេស | ២៨,០០០៛/កេស | ផ្សារលើ | |
| ២ | | មីសៀម | ២០០កេស | ១៩,៥០០៛/កេស | ផ្សារលើ | |
| ៣ | | | | | | |
| III | ផ្នែកលក់ទឹកបរិសុទ្ធ | | | | | |
| ១ | | ទឹកសុទ្ធវីតាល់ | ១០០កេស | ៣.៥$/កេស | ផ្សារលើ | |
| ២ | | ទឹកសុទ្ធធម្មតា | ២០០យួរ | ៣,៥០០៛/យួរ | ផ្សារលើ | |
| ៣ | | | | | | |
| IV | ផ្នែកលក់កៅស៊ូផ្លាស្ទិក | | | | | |
| ១ | | កៅស៊ូតង់ ៤មx៦ម | ២០ | ៧៨,២០០៛/ផ្ទាំង | ផ្សារលើ | |
| ២ | | កៅស៊ូតង់ ៤មx៥ម | ២០ | ៦៥,១០០៛/ផ្ទាំង | ផ្សារលើ | |
| ៣ | | កៅស៊ូតង់ ៤មx៤ម | ២០ | ៤០,០០០៛/ផ្ទាំង | ផ្សារលើ | |

តារាងនេះ គឺសម្រាប់បំពេញព័ត៌មានអំពីមុខទំនិញ បរិមាណ តម្លៃប៉ាន់ស្មាន ទីតាំងផ្គត់ផ្គង់ ឈ្មោះម្ចាស់ហាង និងលេខទូរសព្ទ័ទំនាក់ទំនង គួរធ្វើឡើងនៅតាមទីផ្សារនានាដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន (ផ្សារនៅក្នុងខេត្ត ក្រុង ឬ ស្រុក ខណ្ឌ) ដើម្បីងាយស្រួលដល់ការស្វែងរកទិញ និងសម្រាប់បម្រើឲ្យការឆ្លើយតបបានទាន់ពេលវេលា។ រាល់បណ្តាមុខទំនិញគួរផ្តោតលើប្រភេទទំនិញទាំងឡាយណាដែលចាំបាច់សម្រាប់បម្រើឲ្យការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញរួមមាន៖ អង្ករ អាហារក្រៀម ទឹកសុទ្ធ កៅស៊ូតង់សម្រាប់ធ្វើជម្រក។

## ៦.៧. ប្រពន្ធ័ធារាសាស្រ្ត

| ល រ | ឈ្មោះ ប្រព័ន្ធ រំដោះទឹក និង ស្រោចស្រព | ស្រុក | ឃុំ | ប្រវែង (ម) | បរិមាណ ទឹក ($ម^៣$) | ប្រឡាយ មេ(ម) | ប្រឡាយ រង (ម) | ទ្វារទឹក (កន្លែង) | លូ (កន្លែង) | ទំនប់ បង្ហៀរ (កន្លែង) | សង្គ្រោះស្រូវប្រាំង (ហត) | | សង្គ្រោះ ស្រូវវស្សា (ហត) | | ប្រភពទឹក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | បង្ហៀរ | បូម | បង្ហៀរ | បូម | |
| ១ | ទំនប់ភ្នំស្រួច | ឆ្លូង | ក្បាលដំរី | ១០២៧ | ២ លាន | ១០០០ | ៥០០ | ១ | ៥ | ១ | ១៣ | ៤៥ | ១០៧ | ៨៧ | ទឹកភ្លៀង |
| ២ | ទំនប់អូរប៉ាក | ឆ្លូង | កោះខ្ញែ | ៥៥០ | ៩០០០០ | ៣០០០ | ៤០០០ | ២ | ៧ | ០ | ៩៦ | ៨៣ | ៦៧ | ៦០ | ទន្លេមេគង្គ |
| ៣ | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | |

តារាងនេះ គឺសម្រាប់បំពេញព័ត៌មានអំពីឈ្មោះហេដ្ឋារចនាសម្ព័ន្ធផ្នែកធារាសាស្រ្តនានាដែលមានក្នុងខេត្ត ក្រុង ស្រុក ខណ្ឌ។ សារៈសំខាន់នៃធនធានព័ត៌មានទាំងនេះសម្រាប់បម្រើឲ្យផលប្រយោជន៍ពីរយ៉ាង (១) រំដោះទឹកជំនន់ និង (២)ស្តុក/ទប់ទឹកបម្រើឲ្យការស្រោចស្រពសម្រាប់វិស័យកសិកម្ម។

## IV. ដំណើរការសម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### គោលបំណង៖

ធ្វើការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អារម្ភកថាចុះហត្ថលេខា និងប្រថាប់ត្រាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### សេចក្តីផ្តើម៖

ឧបករណ៍មួយក្នុងចំណោមឧបករណ៍ចម្បងៗទាំងឡាយសម្រាប់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធ ដើម្បីធានានូវការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយ នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកបដោយបទដ្ឋានរួមខ្ពស់គឺការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នដែលនឹងត្រូវបានបង្កើត ឬត្រូវរៀបចំធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ។ វិធីដែលល្អបំផុតសម្រាប់ធ្វើឲ្យផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នកើតមានឡើងពិតប្រាកដគឺតាមរយៈសិក្ខាសាលាតាមបែបចូលរួម។

ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននឹងមានព័ត៌មានពីរកញ្ចប់គឺ៖ ព័ត៌មានមួយដែលប្រមូលដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងព័ត៌មានមួយទៀតគឺផែនការដែលបានកសាងឡើងនៅអំឡុងពេលសិក្ខាសាលាផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន។ នៅក្នុងជំពូកនេះជំហាននៃការធ្វើសិក្ខាសាលាត្រូវបានលើកយកមកពន្យល់ដូចខាងក្រោម៖

### ជំហានទី១៖ សិក្ខាសាលាកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

នៅមុនការរៀបចំសិក្ខាសាលាជំហានទី១ ត្រូវមានការរៀបចំកិច្ចប្រជុំក្រុមការងារ និងអ្នកពាក់ព័ន្ធដើម្បីឯកភាពគ្នារៀបចំផែនការសិក្ខាសាលានេះ។

គោលបំណង៖

ដើម្បីអោយអ្នកចូលរួមទាំងអស់យល់ដឹងអំពីទស្សនទានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងដំណើរការកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយ ។

ប្រធានបទទី១៖ ទស្សនទាននៃគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយ

គោលបំណង៖

ដើម្បីបង្ហាញដល់អ្នកចូលរួមពីរបៀបដែលវិសមភាព និងភាពងាយរងគ្រោះប៉ះពាល់ដល់សមត្ថភាពដើម្បីរស់រានពីគ្រោះមហន្តរាយ និងដើម្បីដោះស្រាយភាពលំបាកនៃគ្រោះមហន្តរាយ។

ប្រធានបទទី២៖ យន្តការ រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ

គោលបំណង៖

ដើម្បីពន្យល់ដល់អ្នកចូលរួមទាំងអស់ពីសមាសភាព និងតួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិព្រមទាំងក្រុមទាំងបួនរបស់ខ្លួន សមាជិករបស់ពួកគេ និងតួនាទី ព្រមទាំងការទទួលខុសត្រូវរបស់ពួកគេផងដែរ។

### ប្រធានបទទី៣៖ ផែនទីភ្នាក់ងារពាក់ព័ន្ធ

គោលបំណង៖

ដើម្បីប្រាប់ប្លង់ផែនទីទៅកាន់គ្រប់ភ្នាក់ងារពាក់ព័ន្ធនៅក្នុងខេត្តដែលទាក់ទងទៅនឹងការត្រៀមរៀបចំ និងការឆ្លើយតបចំពោះគ្រោះមហន្តរាយ។

### ប្រធានបទទី៤៖ មេរៀនបទពិសោធន៍ឆ្លើយតបគ្រោះមហន្តរាយខេត្តកន្លងមក

គោលបំណង៖

ដើម្បីចែករំលែកព័ត៌មានពិស្តារជាមួយអ្នកចូលរួមទាំងអស់ស្តីអំពីគ្រោះមហន្តរាយក្នុងអតីតកាលនៅតាមខេត្ត និងមេរៀនសិក្សាកន្លងមកស្តីពីបទពិសោធន៍នៃការត្រៀមរៀបចំ និងការឆ្លើយតប។

### ប្រធានបទទី៥៖ ផលប៉ះពាល់ពីគ្រោះមហន្តរាយទៅលើស្ត្រី កុមារ និងក្រុមងាយរងគ្រោះ

គោលបំណង៖

ដើម្បីចែករំលែកព័ត៌មានពិស្តារជាមួយអ្នកចូលរួមទាំងអស់ស្តីអំពីរបៀបដែលគ្រោះមហន្តរាយនៅតាមខេត្តបានផ្តល់ផលប៉ះពាល់ជាពិសេសដល់ ស្ត្រី កុមារ និងក្រុមងាយរងគ្រោះ។

### ប្រធានបទទី៦៖ ការវិភាគក្រុមងាយរងគ្រោះ

គោលបំណង៖

ដើម្បីកំណត់ក្រុមដែលងាយរងគ្រោះនៅក្នុងខេត្ត ក្រុង ស្រុក ខណ្ឌ ភាពងាយរងគ្រោះជាក់លាក់របស់ពួកគេ និងសមត្ថភាព និងថាតើពួកគេទទួលផលប៉ះពាល់ពីគ្រោះមហន្តរាយតាមរបៀបណា។

### ប្រធានបទទី៧៖ ការរៀបចំផែនទី មុខសញ្ញាគ្រោះថ្នាក់ និងកម្រិត/ទំហំហានិភ័យ

គោលបំណង៖

ដើម្បីកំណត់មុខសញ្ញាគ្រោះថ្នាក់ដែលខេត្ត ក្រុង ស្រុក ខណ្ឌ រងផលប៉ះពាល់ និងកម្រិតនៃហានិភ័យចំពោះខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ។

### ប្រធានបទទី៨៖សេណារីយ៉ូ និងកម្រិតហានិភ័យ

គោលបំណង៖

ដើម្បីកំណត់នូវផលប៉ះពាល់ និងហានិភ័យដែលទំនងនឹងកើតឡើងបំផុតដែលបានកំណត់។

### ប្រធានបទទី៩៖ ផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន

គោលបំណង៖

កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### ប្រធានបទទី១០៖ វិធីសាស្ត្រដើម្បីកំណត់ធនធាននៅថ្នាក់ក្រោមជាតិ

គោលបំណង៖

ដើម្បីកំណត់ និងគូសផែនទីបង្ហាញពីធនធានមនុស្ស សម្ភារហិរញ្ញវត្ថុ សម្ភារផ្គត់ផ្គង់ និងឧបករណ៍ដែលមាននៅក្នុងខេត្តដើម្បីជួយដល់ការត្រៀមរៀបចំ និងការឆ្លើយតប។

សម្គាល់៖ ទម្រង់ និងឧបករណ៍ទាំងឡាយដែលប្រើប្រាស់សម្រាប់កសាងផែនការនេះមាននៅក្នុងឯកសារបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននៅរាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ។

**ជំហានទី២៖ ក្រុមការងារបូកសរុបបញ្ចូលទិន្នន័យក្នុងឯកសារផែនការ**

ក្រោយសិក្ខាសាលាក្រុមការងាររបស់រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក និងអង្គការពាក់ព័ន្ធធ្វើការប្រជុំម្តងទៀតដើម្បីបញ្ចប់ឯកសារផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្នរួមបញ្ចូលទាំងព័ត៌មានដែលខ្វះចន្លោះដាក់បញ្ចូលលទ្ធផលនៃសិក្ខាសាលា និងបន្ថែមព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធ។

**ជំហានទី៣៖ សិក្ខាសាលាឆ្លងពង្រាងផែនការចុងក្រោយ**

សិក្ខាសាលានេះក្នុងគោលបំណងឲ្យអ្នកចូលរួមកែសម្រួល និងអនុម័តចុងក្រោយលើពង្រាងផែនការ។

**ជំហានទី៤៖** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពិនិត្យសម្រេច និងចុះហត្ថលេខាលើផែនការ បន្ទាប់មកឯកសារនឹងត្រូវដាក់ជូនអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេច និងចុះហត្ថលេខា។

**ជំហានទី៥៖ សិក្ខាសាលាផ្សព្វផ្សាយ និងណែនាំអនុវត្តផែនការ**

ក្រោយពីផែនការបានអនុម័ត និងចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសិក្ខាសាលាផ្សព្វផ្សាយណែនាំ និងចែកចាយផែនការដល់អ្នកពាក់ព័ន្ធទាំងអស់។

**ជំហានទី៦៖ ការត្រួតពិនិត្យការអនុវត្ត និងការធ្វើបច្ចុប្បន្នភាព**

ដើម្បីសម្របសម្រួលការត្រួតពិនិត្យសកម្មភាពត្រៀមរៀបចំ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងកោះប្រជុំរៀងរាល់បីខែម្តងដើម្បីពិភាក្សាជាមួយដៃគូស្តីពីស្ថានភាពនៃការអនុវត្ត ការរីកចម្រើន ឧបសគ្គ ឬកំហិតមួយចំនួន និងវិធានការនានាដើម្បីដោះស្រាយ។

សៀវភៅផែនការនេះត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរាល់មួយឆ្នាំម្តង។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ផ្លូវ ៥១៦, សង្កាត់ទួលសង្កែ, ខណ្ឌឫស្សីកែវ
( ក្បែរអង់តែនទូរទស្សន៍ជាតិកម្ពុជា )
ទូរស័ព្ទ / ទូរសារលេខ: ( ៨៥៥ ) ២៣ ៨៨២ ០៤៥

សហការរៀបចំដោយ ៖